00429026

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 01 / 2010
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

លេខ / No: D250/3/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi
Kingdom of Cambodia
Nation Religion King

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 03 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**លេខសំណុំរឿង: ០០២/១៩-០៩-២០០៧-អ.វ.ត.ក.-ក.ស.ច.ស.**

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩

ភាសាដើម៖ បារាំង/ខ្មែរ

ចំណាត់ថ្នាក់ឯកសារ៖ សម្ងាត់

សាធារណៈ
PUBLIC
05/03/2010

## ដីកាសម្រេចលើភាពអាចទទួលបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងសំណើសុំ D250/3

**សហព្រះរាជអាជ្ញា**
អ្នកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
នី ច័ន្ទឌី
ឡោ ឈុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ិន សុវន
ជេត វណ្ណលី
ពេជ អង្គ
Silke STUDZINSKY
Phillipe CANONNE
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud

**មេធាវីការពារក្តី**
សុន អរុណ Michiel PESTMAN
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស សុវ៉ាន Jacques VERGES
ការ សាវុត្ថ François ROUX
Marie-Paule CANIZARES

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ១២ វិធាន ២១ វិធាន ២៣ វិធាន ៤៩ វិធាន ៥៣ វិធាន ៥៥ និង វិធាន ៦៦ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការស៊ើបសួរ លើឈ្មោះ **នួន ជា** និង **ជននៃទៃ** ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យចំពោះ **បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

បានឃើញមាត្រា ១ និងមាត្រា ៣ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការចូលរួមរបស់ជនរងគ្រោះ ("សេចក្តីណែនាំអនុវត្ត")

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៨ (D83) ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩ (D196) និងថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ (D146/3)

បានឃើញសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទិននឹងអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម និងជនជាតិវៀតណាម (D 250/3)

00429028



# ការរំលឹកឡើងវិញពីនីតិវិធី

១. ស្របតាមវិធាន ១២ នៃវិធានផ្ទៃក្នុង អង្គភាពជនរងគ្រោះនៃ អ.វ.ត.ក បានបញ្ជូនមកសហចៅក្រមស៊ើបអង្កេត នូវរបាយការណ៍ជាច្រើន ដែលមានភ្ជាប់មកជាមួយនឹងសំណើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[1] របស់អ្នកស្នើសុំចំនួនពីរក្រុម ដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនជាតិវៀតណាម និងជាខ្មែរកម្ពុជាក្រោម។

២. *ជនរងគ្រោះដែលមានដើមកំណើតជាជនជាតិវៀតណាម ពីខេត្តកំពង់ឆ្នាំង៖*

- **VN01** – ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 08-VU-02379, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/125
- **VN02** - ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 08-VU-02380, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/171
- **VN03** - ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 08-VU-02378, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/276
- **VN04** - ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 08-VU-02116, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ០២ តុលា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/172
- **VN05** - ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 09-VU-01723, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/277
- **VN06** - ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 09-VU-01722, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/278
- **VN07** - ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 09-VU-02241, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/279

---

[1] លេខយោង XX-VU-XXXX គឺសំដៅទៅលេខចុះបញ្ជីដែលផ្ដល់ឱ្យសំណើសុំតាំងខ្លួនជាដើមរដ្ឋប្បវេណីនេះ ធ្វើឡើងដោយ អង្គភាពជនរងគ្រោះ។ លេខយោងបន្ទាប់ទៀត D22/XXX គឺសំដៅទៅលេខកូដដែលត្រូវគ្នានឹងសំណើសុំតាំងខ្លួនជាដើមរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២។ ចុងក្រោយ អក្សរយោង V, VN, K, KK សំដៅលើអក្សរយោងដែលដាក់ដោយមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងពាក្យសុំ D250/3។

- VN08 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02242, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ដោយដាក់លេខកូដ D22/280
- VN09 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02243, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/281
- VN10 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 08-VU-2291 ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/205
- VN11 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02239 ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/282
- VN12 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02240, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/283
- VN13 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-00687, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/284
- VN14 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-00686, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/285
- VN15 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-00688, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/286
- VN16- ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-00685, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/287[2]។

## ៣. *ជនរងគ្រោះដែលត្រូវបានស្គាល់អត្តសញ្ញាណនៅក្នុងសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ថាជាខ្មែរកម្ពុជាក្រោម*

- KK 01 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02140, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/262
- KK02 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02139, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/261

---

[2] កាលពីថ្ងៃទី ២៣ តុលា ២០០៩ សហចៅក្រមស៊ើបអង្កេត ត្រូវបានជូនដំណឹងដោយមេធាវីម្នាក់ របស់ដើម បណ្តឹងរដ្ឋប្បវេណីនេះថា កូនក្តីរបស់ខ្លួនបានស្លាប់ហើយ។

- KK 03 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02138, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/260
- KK 04 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02137, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/259
- KK 05 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02136, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/258
- KK 06 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02135, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/257
- KK 07- ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02134, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/236
- KK 08 – ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 08-VU-02103, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/253
- KK09 – មកដល់ថ្ងៃចេញដីកានេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនទាន់បានដាក់មកក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទេ
- K10 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02151, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/273
- K11 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02150, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/272
- K12 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02149, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/271
- K13 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02148, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/270
- K14 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02147, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/269
- K15 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02145, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/268
- K16 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02146, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/267

- K17 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02144, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/266
- K18 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02143, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/265
- K19 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02142, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/264
- KK 20 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02141, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/263
- KK 21 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-00638, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/134
- KK 22 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 08-VU-02267, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/135
- KK 23 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-00641, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/101
- KK 24 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 08-VU-02130, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/102
- K 25 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 08-VU-02131, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៩ ដោយដាក់លេខកូដ D22/132
- KK 26 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-04265, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/274
- KK27 - ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-04266, ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០ ដោយដាក់លេខកូដ D22/275

៤. នៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០០៩ ដើមបណ្តឹងរដ្ឋប្បវេណីខាងលើ បានស្នើសុំសហចៅក្រមស៊ើបអង្កេត ឱ្យ "ពិចារណាលើភស្តុតាងថ្មីៗ ទាក់ទិននឹងបទឧក្រិដ្ឋដែលប្រព្រឹត្តលើខ្មែរក្រោម នៅក្នុងខេត្តពោធិសាត់ និងខេត្តតាកែវ នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបន្ថែមការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាក់ទិននឹងការប្រព្រឹត្តចំពោះ

ជនជាតិវៀតណាម"[3]។

៥. ម្យ៉ាងទៀត មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាលើការផ្តល់ជូនវិធានការការពារដល់កូនក្តីរបស់ខ្លួន។ មេធាវីលើកឡើងថា នៅអំឡុងពេលនៃការរង់ចាំលទ្ធផលនៃការវាយតំលៃទៅលើហានិភ័យចំពោះអាយុជីវិតរបស់កូនក្តីខ្លួន ក្រុមគ្រួសារ និងទ្រព្យសម្បត្តិរបស់ពួកគេ និងសេចក្តីសម្រេចរបស់របស់សហចៅក្រមស៊ើបអង្កេតនោះ ព័ត៌មាននានាដែលទាក់ទិននឹងកូនក្តីរបស់ខ្លួនមិនត្រូវលាតត្រដាងឱ្យសាធារណជន ឬមេធាវីរបស់ជនត្រូវចោទដឹងទេ[4]។

**ហេតុផលនៃសេចក្តីសម្រេច**

៦. ដោយអនុវត្តតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត អាចសម្រេចតាមរយៈការចេញដីកាដោយមានបញ្ជាក់ហេតុផល បដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលណាក៏បានរហូតដល់ពេលចេញដីកាដំណោះស្រាយ។

**I. លក្ខខណ្ឌផ្ទាល់ខ្លួននៃភាពអាចទទួលបាន នៃការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ (par voie d'intervention)**

៧. វិធាន ២៣(១) នៃវិធានផ្ទៃក្នុង ចែងថា *"គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី ៖*

*ក-ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង*

*ខ-អនុញ្ញាតឱ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាននេះ។"*

---

[3] D 250/3 សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទិននឹងប្រល័យពូជសាសន៍ទៅលើ ខ្មែរក្រោម និងជនជាតិវៀតណាម កថាខ័ណ្ឌ ១។

[4] សូមអានផ្នែក VI នៃសំណើសុំ។

00429033



៨. ហេតុដូច្នេះ នៅចំពោះមុខ អ.វ.ត.ក ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[5] ជនរងគ្រោះដែលមានបំណងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបានតែតាមផ្លូវអន្តរាគមន៍ប៉ុណ្ណោះ ដោយភ្ជាប់ការស្នើសុំរបស់ខ្លួនជាមួយនឹងបណ្តឹងអាជ្ញាដែលកំពុងដំណើរការ[6]។

៩. សហចៅក្រមស៊ើបអង្កេត ត្រូវគោរពគោលការណ៍ជាមូលដ្ឋាន ដែលតាមរយៈគោលការណ៍នេះ ខ្លួនមិនអាចសម្រេចលើសពីអង្គហេតុដែលបានប្តឹងដោយសហព្រះរាជអាជ្ញាទេ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏មិនអាចពង្រីកបណ្តឹងនេះដែរ នៅពេលដែលការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងតាមផ្លូវអន្តរាគមន៍។

១០. ដូច្នេះការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់កំហិត ដោយសារវាមិនអាចប្តឹងពីអង្គហេតុថ្មីទៅសហចៅក្រមស៊ើបអង្កេត នៅអំឡុងពេលនៃកិច្ចស៊ើបសួរ ដោយមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមជាមុនពីសហព្រះរាជអាជ្ញាទេ[7]។

១១. ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយអាចទទួលយកបាន អ្នកដាក់ពាក្យសុំចាំបាច់ត្រូវតែបង្ហាញថា ព្យសនកម្មរបស់ខ្លួនគឺបណ្តាលមកពីអង្គហេតុ ដែលត្រូវបានបើកការស៊ើបសួរតែប៉ុណ្ណោះ ដូចជាករណីស្ថានភាពជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង និងនៅពេលមានការចូលលុកលុយប្រទេសវៀតណាម។

---

[5] មាត្រា ១៣៨ ដល់មាត្រា ១៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)

[6] យោងមាត្រា ១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អំពី **ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍** "កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថា ជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបអង្កេតគ្រប់ពេលវេលា"។
ផងដែរ មាត្រា ៣.១ និង ៣.៣ នៃវិធានសេចក្តីណែនាំអនុវត្ត ដែលចែងថា *"ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក អាចចូលរួមក្នុងកិច្ចដំណើរការជំនុំជម្រះជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងស៊ើបអង្កេតនៃបទឧក្រិដ្ឋនេះ"* និង *"ជនរងគ្រោះ អាចដាក់ពាក្យសុំដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែនៅពេលដែលសំណុំរឿងស្ថិតនៅក្នុងកិច្ចស៊ើបសួរ ដោយចៅក្រមស៊ើបអង្កេត"*។

[7] សូមអាន ផងដែរ មាត្រា ៣.១ និង ៣.៣ នៃវិធានសេចក្តីណែនាំអនុវត្ត ដែលចែងថា *"ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក អាចចូលរួមក្នុងកិច្ចដំណើរការជំនុំជម្រះជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងស៊ើបអង្កេតនៃបទឧក្រិដ្ឋនេះ"* និង *"ជនរងគ្រោះ អាចដាក់ពាក្យសុំដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែនៅពេលដែលសំណុំរឿងស្ថិតនៅក្នុងកិច្ចស៊ើបសួរ ដោយចៅក្រមស៊ើបអង្កេត"*។

១២. សហចៅក្រមស៊ើបអង្កេត នឹងពិនិត្យមើលផងដែរថា តើព្យសនកម្មទាំងនេះ មានទំនាក់ទំនងដែរ ឬទេ ជាមួយនឹងអង្គហេតុដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

## II. ការពិនិត្យមើលពីករណីនីមួយៗ នៃការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

១៣. ដើម្បីអាចទទួលយកបាន ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវឆ្លើយតបទៅនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ២៣ នៃវិធានផ្ទៃក្នុង និងមាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការចូលរួមរបស់ជនរងគ្រោះ គឺ៖

ក) អ្នកប្តឹងត្រូវតែជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មណាមួយ ស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក។

ខ) ដើម្បីត្រូវបានកំណត់ថាបានរងព្យសនកម្ម អ្នកប្តឹងត្រូវបង្ហាញ៖

-ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និង

-ព្យសនកម្ម គឺជាផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនោះ និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន។

គ) ការខូចខាតផ្លូវចិត្ត អាចគិតទាំងការស្លាប់ញាតិសន្តាន ដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ។

១៤. ស្របតាមវិធាន ២៣.៥ ពាក្យសុំនេះត្រូវ "មានព័ត៌មានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យបណ្តឹងជាមួយនឹងវិធានផ្ទៃក្នុងនេះ។ ជាពិសេសពាក្យបណ្តឹងត្រូវផ្តល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវចោទប្រកាន់។"

១៥. យោងតាមការបកស្រាយខាងលើ សហចៅក្រមស៊ើបអង្កេត នឹងវាយតំលៃពីភាពសមហេតុសមផលនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីកំណត់ថាតើ ពាក្យសុំទាំងនេះបំពេញ ឬមិនបំពេញលក្ខខណ្ឌដែលបានរៀបរាប់ខាងលើ។ នៅក្នុងសេចក្តីសម្រេចនេះ សហចៅក្រមស៊ើបអង្កេត នឹងផ្តល់តែព័ត៌មានណាដែលចាំបាច់សម្រាប់អ្នកស្នើសុំម្នាក់ៗប៉ុណ្ណោះ។

សេចក្ដីសង្ខេបខ្លឹមសារនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ដោយពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នឹងភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្ដី សម្រេចនេះ[8]។

១៦. ជាបឋម សហចៅក្រមស៊ើបអង្កេត កត់សំគាល់ឃើញថា អ្នកស្នើសុំទាំងអស់ បានផ្ដល់ភស្ដុតាងបញ្ជាក់ពីអត្ដសញ្ញាណ និងពីអាសយដ្ឋាននៅក្នុងប្រទេសកម្ពុជា ហេតុដូចនេះ ពួកគេ បានបញ្ជាក់ច្បាស់ថា ពួកគេគឺជារូបវន្ដបុគ្គល ហើយអត្ដសញ្ញាណរបស់ពួកគេដែលផ្ដល់មកក៏មានលក្ខណៈគ្រប់គ្រាន់ដែរ។

១៧. ម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេត ក៏កត់សំគាល់ឃើញដែរថា អ្នកស្នើសុំទាំងអស់បានផ្ដល់ភស្ដុតាងគ្រប់គ្រាន់ ដែលអាចជឿជាក់បានថាមានព្យសនកម្មផ្ទាល់ខ្លួន និងដោយផ្ទាល់ពីឧក្រិដ្ឋកម្ម។ ប៉ុន្ដែ ចំណងទាក់ទងរវាងព្យសនកម្មនេះ និងអង្គហេតុ ដែលបានប្ដឹងសហចៅក្រមស៊ើបអង្កេត មិនមានទេសម្រាប់អ្នកស្នើសុំមួយចំនួន។

១៨. សហចៅក្រមស៊ើបអង្កេត សូមរំលឹកសារជាថ្មីថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើឡើង ដូចមានចែងនៅក្នុងវិធាន ២៣ នៃវិធានផ្ទៃក្នុង អាចទទួលយកបានតែចំពោះអង្គហេតុទាំងឡាយណាដែលបានបើកកិច្ចស៊ើបសួរប៉ុណ្ណោះ។

១៩. យោងតាមអ្វីដែលបានលើកឡើងខាងលើនេះ ពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីខាងក្រោមអាចទទួលយកបាន ដោយសារអ្នកដាក់សំណើបានបង្ហាញភស្ដុតាងត្រឹមត្រូវគ្រប់គ្រាន់ដើម្បីបញ្ជាក់តាមទិដ្ឋភាពខាងក្រៅដោយសន្មតថា ព្យសនកម្មដែលខ្លួនទទួលរង គឺជាផលវិបាកដោយផ្ទាល់នៃអង្គហេតុ ដែលជាកម្មវត្ថុនៃការស៊ើបសួរ ដូចមានពិពណ៌នានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿងលេខ ០០២៖

ក. 09-VU-02140 (D22/262), 09-VU-02139 (D22/261) et 09-VU-02137 (D22/259) ក្នុងឋានៈជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃព្រះពុទ្ធសាសនានៅលើទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ ស្របទៅតាមសមត្ថកិច្ចដែនដីរបស់

---

[8] ព័ត៌មានដែលមាននៅក្នុងឧបសម្ព័ន្ធ គឺបានមកពីរបាយការណ៍របស់អង្គភាពជនរងគ្រោះសម្រាប់អ្នកដាក់ពាក្យសុំម្នាក់ៗ ដែលផ្ញើពីអង្គភាពជនរងគ្រោះមកសហចៅក្រមស៊ើបអង្កេត។

00429036



អ.វ.ត.ក. (កថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) និង ក្នុងឋានៈជាជនរងគ្រោះនៃការចូលលុកលុយរបស់ខ្មែរក្រហមក្នុងទឹកដីវៀតណាម ក្នុងឆ្នាំ ១៩៧៨ (កថាខណ្ឌ ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) ។

ខ. 09-VU-02134 (D22/236), 08-VU-02131 (D22/132) ក្នុងឋានៈជាជនរងគ្រោះនៃការចូលលុកលុយរបស់ខ្មែរក្រហមក្នុងទឹកដីវៀតណាម ក្នុងឆ្នាំ ១៩៧៨ (កថាខណ្ឌ ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) ។

គ. 09-VU-02135 (D22/257), 08-VU-02103 (សូមមើលផងដែរ 09-VU-02133) D22/253 ក្នុងឋានៈជាជនរងគ្រោះនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ (កថាខណ្ឌ ៣៧-៣៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) ។

ឃ. 09-VU-02149 (D22/271) ក្នុងឋានៈជាជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ថ្ងៃ ៣០ មេសា ២០០៩)

ង. 09-VU-04266 (D22/275) ក្នុងឋានៈជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំចេញពីភូមិភាគបូព៌ា និងជាពិសេសចេញពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ទៅកាន់ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង (កថាខណ្ឌ ៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) ។

២០. ផ្ទុយមកវិញ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា អ្នកដាក់សំណើខាងក្រោម មិនបានបង្ហាញអំពីទំនាក់ទំនងហេតុ និងបច្ច័យ រវាងព្យសនកម្មដែលអះអាង និងអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរ 08-VU-02379 (D22/125), 08-VU-02380 (D22/171), 08-VU-02378 (D22/276), 08-VU-02116 (D22/172), 09-VU-01723 (D22/277), 09-VU-01722 (D22/278), 09-VU-02241(D22/279), 09-VU-02242 (D22/280), 09-VU-02243 (D22/281), 09-VU-02136 (D22/258), 09-VU-02239 (D22/282), 08-VU-2291 (D22/205), 09-VU-02240 (D22/283), 09-VU-00687 (D22/284), 09-VU-00686 (D22/285), 09-VU-00688 (D22/286), 09-VU-00685 (D22/287), 09-VU-02138 (D22/260), 09-VU-02151 (D22/273), 09-VU-02150 (D22/272), 09-VU-02148 (D22/270), 09-VU-02147 (D22/269), 09-VU-02145 (D22/267), 09-VU-02146 (D22/268), 09-VU-02144 (D22/266), 09-VU-02143 (D22/265), 09-VU-02142 (D22/264), 09-VU-02141 (D22/263), 09-VU-00638 (D22/134), 08-VU-02267 (D122/135), 09-VU-00641 (D22/101), 08-VU-02130 (D22/102), 09-VU-04265 (D22/274) ដោយហេតុថា អង្គហេតុដែលបានលើកឡើងមានលក្ខណៈខុសគ្នាស្រឡះពីអង្គហេតុដែល ត្រូវបានប្ដឹងមក សហចៅក្រមស៊ើបអង្កេត និងដោយសារថា មិនមានកាលៈទេសៈណាមួយអាចបញ្ជាក់អំពីទំនាក់ទំនងដោយផ្ទាល់រវាងព្យសនកម្មដែលអះអាង និងបទល្មើសដែលជាកម្មវត្ថុនៃការស៊ើបសួរនោះទេ៖ ជាក់ស្ដែង អនុលោមតាមកថាខណ្ឌ ៦៩ និង ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតត្រូវបានប្ដឹងមកអំពីអង្គហេតុ

ដែលទាក់ទងជាមួយនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងក្នុងអំឡុងពេលចូលលុកលុយក្នុងទឹកដីវៀតណាម។ សហចៅក្រមស៊ើបអង្កេត មិនត្រូវបានប្តឹងអំពីអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងខ្មែរក្រោម នៅក្នុងខេត្តពោធិ៍សាត់ និងខេត្តតាកែវ ឬអំពីបញ្ហាដែលពាក់ព័ន្ធជាមួយនឹងជនជាតិភាគតិចវៀតណាមនៅក្នុងខេត្តកំពង់ឆ្នាំងនោះទេ។

**អាស្រ័យហេតុនេះ**

**សម្រេច**

- ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 09-VU-02140 (D22/362), 09-VU-02139 (D22/261) et 09-VU-02137 (D22/259), 09-VU-02134 (D22/236), 08-VU-02131 (D22/132), 09-VU-02136 (D22/258), 09-VU-02135 (D22/257), 08-VU-02103 (also 09-VU-02133), D22/253, 09-VU-02149 (D22/271) et 09-VU-04266 (D22/275) ត្រូវទទួលយក។

- ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 08-VU-02379 (D22/125), 08-VU-02380 (D22/171), 08-VU-02378 (D22/276), 08-VU-02116 (D22/172), 09-VU-01723 (D22/277), 09-VU-01722 (D22/278), 09-VU-02241(D22/279), 09-VU-02242 (D22/280), 09-VU-02243 (D22/281), 08-VU-2291 (D22/205), 09-VU-02239 (D22/282), 09-VU-02240 (D22/283), 09-VU-00687 (D22/284), 09-VU-00686 (D22/285), 09-VU-00688 (D22/286), 09-VU-00685 (D22/287), 09-VU-02136 (D22/258), 09-VU-02138 (D22/260), 09-VU-02151 (D22/273), 09-VU-02150 (D22/272), 09-VU-02148 (D22/270), 09-VU-02147 (D22/269), 09-VU-02145 (D22/267), 09-VU-02146 (D22/268), 09-VU-02144 (D22/266), 09-VU-02143 (D22/265), 09-VU-02142 (D22/264), 09-VU-02141 (D22/263), 09-VU-00638 (D22/134), 08-VU-02267 (D122/135), 09-VU-00641 (D22/101), 08-VU-02130 (D22/102) et 09-VU-04265 (D22/274) ត្រូវបដិសេធចោល។

**សម្រេច** សំណើសុំវិធានការការពារ ដែលដាក់ដោយអ្នកដាក់សំណើ 08-VU-02379 (D22/125), 08-VU-02380 (D22/171), 08-VU-02378 (D22/276), 08-VU-02116 (D22/172), 09-VU-01723 (D22/277), 09-VU-01722 (D22/278), 09-VU-02241(D22/279), 09-VU-02242 (D22/280), 09-VU-02243 (D22/281), 08-VU-2291 (D22/205), 09-VU-02239 (D22/282), 09-VU-02240 (D22/283), 09-VU-00687 (D22/284), 09-VU-00686 (D22/285), 09-VU-00688 (D22/286) et 09-VU-00685 (D22/287) ត្រូវបានចាត់ទុកថាគ្មានកម្មវត្ថុ ព្រោះសំណើសុំ

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធត្រូវបានបដិសេធចោល និងត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿងលេខ ០០២។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juges d'instruction

**Marcel LEMONDE**

យូ ប៊ុនឡេង